**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា**
**នរោត្តម មុនិនាថ សីហនុ**
**នៃព្រះរាជាណាចក្រកម្ពុជា**

ជូន	លោក ឆាំង យុ
	នាយក
	នៃមជ្ឈមណ្ឌលឯកសារកម្ពុជា
	និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត

លោកនាយក

ខ្ញុំ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលិខិតថ្វាយព្រះពរជ័យ នៅក្នុងឱកាសបុណ្យចម្រើនព្រះជន្មាយុ ខ្ញុំ គម្រប់៨៧ យាងចូល ៨៨ ព្រះវស្សា ដែលបានផ្តល់យុត្តិធម៌ដល់ ខ្ញុំ ក្នុងការបម្រើប្រជាជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា ព្រមជាមួយតង្វាយក្រណាត់សូត្រចំនួន ២ក្បិន ។

ក្រណាត់សូត្រនេះស្អាត ដែលជាស្នាដៃរបស់អ្នកតម្បាញជនជាតិខ្មែរ-ឥស្លាមក្រោមគម្រោងឧបត្ថម្ភពីស្ថានទូត Türkiye ។

សូមលោកនាយក និងបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងបុគ្គលិក "**បណ្ណាល័យសម្តេចម៉ែ**" ទាំងអស់បានប្រកបតែនឹងព្រះពុទ្ធពរគ្រប់ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងទទួលនូវសេចក្តីរាប់អាន អំពីខ្ញុំ ។

ន មុនិនាថសីហនុ

**នរោត្តម មុនិនាថ សីហនុ**

ភ្នំពេញ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២៣